

# ប៉ុទុម និងសាគរ

Prum Kunthearo

Sin Thuokna

Let's Read

The Asia Foundation



គ្រួសារបុទុមរស់នៅក្នុងភូមិសាគរក្បែរជើងភ្នំ។ ព្រឹកថ្ងៃអាទិត្យមួយ ពេលដែលបុទុម និងម្ដាយកំពុងបោចស្មៅបន្លែ...
ស្រាប់តែមានកូនដំរីមួយបោលយ៉ាងលឿនចូលទៅក្រោមផ្ទះ។



បុទុមរត់មកយ៉ាងលឿន ចាប់ទាញ កន្ទុយកូនដំរីដោយ
និយាយ៖ «ទៅផ្ទះឯងវិញទៅ! ខូចជង្រុក ស្រូវខ្ញុំអស់ហើយ!»



ម្តាយដើរចូលមក រួចនិយាយ៖ «កុំធ្វើអីចឹងអីកូន! វាគួរឱ្យអាណិតណាស់។ ប្រហែលជាមានគេកាប់ឈើ ឬប្រមាញ់សត្វក្នុងព្រៃហើយ!» ស្របពេលនោះ ឪពុកមកដល់ ក៏និយាយបន្ថែម៖ «ទុកវាឱ្យនៅមួយរយៈសិនទៅកូន។ យើងដាក់ឈ្មោះវាថាសាគរ។»



សាគរតែងតែមានមុខស្រពោន។ បុទុមមានចិត្តច្រណែនព្រោះម្ដាយឪពុកនាងយកចិត្តទុកដាក់សាគរជាងខ្លួន។ ពួកគាត់ដាក់ចំណីយ៉ាងច្រើនឱ្យសាគរស៊ី។





បុទុមតែងតែរអ៊ូម្នាក់ឯង៖ «តើថ្ងៃណាទើបកូនដំរីទៅផ្ទះវាវិញ ហ្ន៎? វារំខានខ្ញុំមែនទែន! គួរឱ្យធុញណាស់! »





ដោយស្អប់កូនដំរី បុទុមក៏យកស្រមោចមកបន្លាចសាគរ ដោយដាក់ម្រេចចំប្រមោយសាគរ។ សាគរកណ្តាស់ឆែតៗ។ បន្ទាប់មកសាគរឈឺ។ តាំងពីពេលនោះមកបុទុមចាប់ផ្តើម អាណិតសាគរតិចៗ។



ព្រឹកមួយ មុនទៅសាលារៀន បុទុមបេះត្របែកផ្ញើមិត្តភក្តិ។ បុទុមប្រឹងឈោងបេះត្របែកធំមួយនៅចុងមែកខ្ពស់។ កូនដំរីឃើញដូចនោះក៏ជួយទាញបន្ទាបមែកឱ្យបុទុមបេះ។



បុទុមបេះផ្លែត្របែកហើយនិយាយទាំងមុខស្មើ៖ «អរគុណ...!» ភ្លាមនោះបុទុមនិយាយដោយភ្ញាក់៖ «យី! រវល់តែបេះផ្លែត្របែក ខ្ញុំទៅរៀនយឺតហើយម៉ែ!» ម្ដាយបានស្រែកមកពីចម្ងាយ ៖ «កូនឯងជិះសាគរទៅ!»




បុទុមមករៀនទាន់ពេលដោយសារសាគរជូនមក។





ចាប់ពីថ្ងៃនោះមក សាគរមកសាលារៀនជាមួយបុទុមរាល់ថ្ងៃ។
ពេលចេញលេង បុទុម និងមិត្តភក្តិតែងតែលេងជាមួយសាគរ
យ៉ាងរីករាយ។
លោតអន្ទាក់
ទាញព្រ័ត្រ





ទោងរំអិល
លោតមឹក



នៅក្នុងថ្នាក់រៀន អ្នកគ្រូបានសួរទៅសិស្សទាំងអស់ថា ៖ «តើពេលកូនៗធំឡើងចង់ធ្វើអ្វី?»



បុទុមក្រោកឈរឆ្លើយ ៖ «ខ្ញុំចង់ក្លាយជាអ្នកធ្វើការផ្នែកព្រៃឈើ! ខ្ញុំនឹងជួយសាគររកមេរបស់គេ ខ្ញុំចង់ការពារផ្ទះ គ្រួសារ និង មិត្តភក្តិរបស់វា។» អ្នកគ្រូសួរបន្ត៖ «ល្អណាស់! ចុះកូនៗ ផ្សេងទៀត?» ស្រាប់តែមានសំឡេង វូមវូម! វូមវូម! វូមវូម!



អ្នកគ្រូ បុទុម និងមិត្តរួមថ្នាក់ក៏ចេញមកមើល។ សាគរ និងមេ
កំពុងតែឈររលាស់កន្ទុយនៅជិតគ្នា។



បុទុម ឱបសាគរ ហើយនិយាយ ៖ «ឯងត្រលប់ទៅព្រៃជាមួយ
នឹងមេរបស់ឯងវិញចុះ! ពុកម៉ែពិតជាសប្បាយចិត្ត!»



ទាំងអស់គ្នាលើកដៃគ្រវីលាសាគរ និងមេរបស់វា។ បុទុមស្រែក
ប្រាប់៖ «កុំភ្លេចមកលេងពួកយើងផងណា!»



The Asia Foundation

CONSERVATION INTERNATIONAL

អង្គការអភិរក្សអន្តរជាតិ (CI) បានធ្វើការក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ២០០១ ដើម្បីអភិរក្សជីវៈចម្រុះក្នុងប្រទេសកម្ពុជា ក្នុងតំបន់ជួរភ្នំក្រវាញនៃទិសនិរតីដែលជាតំបន់ជំរកសត្វដ៏វិសេសសល់ក្នុងប្រទេស និងតំបន់បឹងទន្លេសាប ដែលជាតំបន់នៃសាទទឹកសាបធំជាងគេក្នុងតំបន់អាស៊ីអាគ្នេយ៍ និង តំបន់ឧទ្យានជាតិវីរៈនសៃ សៀមប៉ាង ដែលជាជំរកសត្វទោចថ្គាល់លឿង។

សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់៖

https://www.conservation.org/where/Pages/Greater-Mekong-region.aspx

https://www.youtube.com/watch?v=XGlTHR8aD-o

https://www.youtube.com/watch?v=xgqsniNBhgs

Generously supported by SMART

Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*បុទុម និងសាគរ (The Elephant in My House)*, Author: Prum Kunthearo. Illustrator: Sin Thuokna. Published by The Asia Foundation - Let’s Read, © The Asia Foundation - Let’s Read. Released under CC-BY-NC-4.0.

This work is a modified version of the original story. © The Asia Foundation, 2019. Some rights reserved. Released under CC-BY-NC-4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/